# សំនេរក្នុងសម័យខេមរយានកម្ម

សូ មុយឃៀង

ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០០

# សំនេរក្នុងសម័យខេមរយានកម្ម

កាលពីថ្ងៃទី១០ដល់១៣ កក្កដា ១៩៦៧ សមាជជាតិលើកទី២៣ បានសំរេចអោយប្រើភាសាខ្មែរជាទូទៅក្នុងកិច្ចការរដ្ឋបាល និងការសិក្សា។ ក្នុងសម័យប្រជុំថ្ងៃទី១៤ កក្កដា ១៩៦៧ អ្នកទទួលខុសត្រូវខាងអប់រំនៃក្រសួងអប់រំជាតិបានសំរេចអោយអនុវត្តខេមរយានកម្មគ្រប់មុខវិជ្ជានៅមធ្យមសិក្សានៅថ្នាក់ទី៦ចាប់ពីឆ្នាំសិក្សា១៩៦៧-៦៨តទៅ។ នៅថ្ងៃទី១៨ កញ្ញា ១៩៦៧ ក្រសួងអប់រំជាតិបានចេញប្រកាសលេខ ២២៩៤ ចុះថ្ងៃទី១៨/៩/៦៧ បញ្ជាអោយអនុវត្តខេមរយានកម្មក្នុងមធ្យមសិក្សាចេញពីថ្នាក់ទី៦ ចាប់ពីបវេសនកាលសិក្សា១៩៦៧-៦៨តទៅ។

តាមរយៈបំរើបំរាស់ពាក្យខេមរយានកម្មតាំងពីឆ្នាំ១៩៦៧រហូតដល់ឆ្នាំ១៩៧៥ យើងអាចចែករបៀបសរសេរពាក្យខេមរយានកម្មជា២ដំនាក់គឺ

- ដំនាក់ទី១ ចាប់ពីឆ្នាំ១៩៦៧ ដល់ ១៩៧២
- ដំនាក់ទី២ ចាប់ពីឆ្នាំ១៩៧២ ដល់ ១៩៧៥ ។

## *I. ដំនាក់ទី១*

ដំនាក់ទី១ ជាដំនាក់ដំបូងផ្តើមការងារនិពន្ធសៀវភៅខេមរយានកម្ម។ អង្គការខេមរយានកម្មបានជួបប្រទះការលំបាកគ្រប់បែបយ៉ាង ។ ទៅពេលនោះ មានតែគណៈកម្មការបច្ចេកទេសតាមមុខវិជ្ជាប៉ុននោះដែលបានខិតខំបកប្រែពាក្យគន្លឹះពីភាសាបារាំងអោយបានគ្រប់គ្រាន់តាមតំរូវការនៃមុខវិជ្ជានីមួយៗ ។ ពាក្យគន្លឹះបង្កើតបាន ហើយ គណៈកម្មការផ្ញើត្រង់ទៅគណៈកម្មការវប្បធម៌តែម្តង ។ តាមរយៈទស្សនាវដ្តីខេមរយានកម្មឆ្នាំ១៩៦៧ ដល់ ១៩៧១ យើងអាចស្រង់ពាក្យខ្លះមកធ្វើជាឧទាហរណ៍បញ្ជាក់សំនេរពាក្យនៅសម័យនោះ ។

### *១. ពាក្យខ្មែរ*

| | | | | | |
|---|---|---|---|---|---|
| ចម្ងាយ | (distance) | តម្លៃ | (valeur) | បម្រាប់ | (donnée) |
| កម្ពស់ | (hauteur) | សម្រិត | (décanter) | សម្រេះ | (reprise) |
| មេចំឡុង | (vecteur) | ប្រឡាយបញ្ជូលទឹក | | | (rigole d'irrigation) |

ដូច្នេះ (donc) ភ្ជាប់ (adapter) ឫស(racine)

ផ្ទៃរថយហ្វ្លងរង្វើល (point arrière)

នាទីអ្នកហ្វឹកហ្វឺន (rôle de formateur)

មហាហ៊្មតសករាជ (ère musulmane) ។

សំនេរពាក្យខាងលើបញ្ជាក់ថា ខេមរយានកម្មពេលនោះ សរសេរពាក្យគន្លឹះទាំងនោះ តាមគោលការណ៍របស់វចនានុក្រមពុទ្ធសាសនបណ្ឌិត្យបោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧-៦៨ ។

*២. ពាក្យខ្ចីពីបាលីសំស្ក្រឹត*

| | | | |
|---|---|---|---|
| ចតុកោណ | (quadrilatère) | ចតុប្បាទ | (quadrupède) |
| ឆ្អឹងលលាដ៍ក្បាល | (os de crâne) | បៀវត្សរ៍ | (traitement) |
| គំនរឧស | (bûcher) | ការអត់ឱន | (tolérance) |
| ការអនុវត្តន៍ | (application) | ការពិសោធន៍ | (expérience) ។ |

សំនេរពាក្យខាងលើបញ្ជាក់ថា ខេមរយានកម្មពេលនោះ សរសេរពាក្យគន្លឹះទាំងនោះ តាមគោលការណ៍របស់វចនានុក្រមពុទ្ធសាសនបណ្ឌិត្យបោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧-៦៨ (ដូចជាការសរសេរស្រៈពេញតួ ការនិយមទំរង់"ការ + នាម") ។

*៣. ពាក្យខ្ចីពីបរទេសផ្សេងទៀត*

| | | | |
|---|---|---|---|
| បំពង់ប៊ែរម៉ាន់ | (tube Bergman) | ពែក្ស | (Perse) |
| បារ៉ូម៉ែត្រ | (baromètre) | ផលហ្ស៊ូល | (effet Joule) |
| ព្រៃហ្គារីក | (garrigue) | ព្យុះទីហ្វុង | (typhon) |
| ជីហ្វូសហ្វាត | (engrais phosphaté) | ស៊ីវ៉ាលីយេរ | (chevalier) |
| បាល្លុង | (ballon) | ពិកនិក | (pique-nique) |
| កាតូដ | (cathode) | អាស៊ីដ | (acide) |
| អាម៉ូនីញ៉ាក់ | (ammoniac) | អាលុយមីនីញ៉ូម | (aluminium) |
| ទួណឺវីស | (tournevis) ។ | | |

សំនេរពាក្យខាងលើបញ្ជាក់ថា ខេមរយានកម្មពេលនោះ សរសេរពាក្យគន្លឹះខ្ចីពីបរទេសក្រៅពីបាលីសំស្ក្រឹត តាមគោលការណ៍របស់វចនានុក្រមពុទ្ធសាសនបណ្ឌិត្យបោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧-៦៨(ដូចជាការសរសេរតាមជាតិសព្ទ ការប្រើអក្សរគ្រួតតួ"ហ្គ ហ្ស ហ្វ ស្ហ..." ការសរសេរព្យាង្គតំរួតរបៀប"បាល្លុង"ការជ្រើសរើសព្យញ្ជនៈប្រកបតាមតួអក្សរបរទេស(អាស៊ីដ))។

## II. *ដំណាក់ទី២*

ដំនាក់ទី២ ជាដំនាក់រៀបចំក្បួនខ្នាតសំរាប់សរសេរ។ ក្នុងដំនាក់នេះ មានគណៈកម្មការពីរកើតឡើងបន្ថែមគឺ គណៈកម្មការអនុម័តពាក្យ គណៈកម្មការចំរុះខាងភាសាខ្មែរ។ គណៈកម្មការចំរុះសំរេច"គោលប្រែពាក្យ"ឯគណៈកម្មការអនុម័តពាក្យយក"គោលប្រែពាក្យ"ទៅអនុវត្តក្នុងការសរសេរពាក្យខេមរយានកម្ម។ តាមរយៈសទ្ទានុក្រមខេមរយានកម្ម យើងអាចស្រង់ពាក្យខ្លះមកធ្វើជាឧទាហរណ៍បញ្ជាក់ដូចតទៅ :

### *១. ពាក្យខ្មែរ*

| | | | |
|---|---|---|---|
| ចំងាយ | (distance) | តំលៃ | (valeur) |
| បំរាប់ | (donnée) | កំពស់ | (hauteur) |
| សំរិត | (décanter) | សំរេះ | (reprise) |
| មេចំលង | (vecteur) | ប្រលាយបញ្ចូលទឹក | (rigole d'irrigation) |
| ដូចនេះ | (donc) | ផ្សុំ | (adapter) |
| រឹស | (racine) | | |

| | |
|---|---|
| តំកល់សីតុណ្ហភាពអោយនៅដដែល | (mainterir la température constante) |
| ចាប់ជើងរោបចង្កេះបោកបញ្ច្រាស | (ramassement de jambe et de ceinture à rebours) |
| ថ្នេរថយឡាំងរង្វើល | (point arrière) |
| នាទីអ្នកវ៉ិកវ៉ឺន | (rôle de formateur) |
| មហាម៉ាត់សករាជ | (ère musulmane)។ |

ឧទាហរណ៍ខាងលើបង្ហាញអោយឃើញទំនោរថ្មីរបស់អង្គការខេមរយានកម្មក្នុងការសរសេរពាក្យគន្លឹះដូចជា:

- សំនេរពាក្យតាមក្បួនព្យាង្គរាយ (ដូចនេះ) តាមក្បួនដំលើ ( ̊ ) (តំលៃ)
- សំនេរពាក្យដោយរក្សាពាក្យរឹសអោយនៅដដែល (ប្រលង)
- សំនេរពាក្យតាមក្បួនមូលភេទ (ផ្សុំ)
- សំនេរពាក្យដោយសំរួល (ឫ>រឹ ឭ>លឹ ឱ>អោ ហ្វ>វ៉ ហ្ម>ម៉ ហ្ល>ល រឺ ឡ) ។

កំ.សំ. បើយើងពិនិត្យមើលសំនេរពាក្យក្នុងវចនានុក្រមពុទ្ធសាសនបណ្ឌិត្យ យើងនឹងឃើញមានតំរាយខ្លះៗសំរាប់អោយខេមរយានកម្មកែលំអសំនេរពាក្យគន្លឹះរបស់ខ្លួនអោយមានឯកភាព ។

(១). ព្យាង្គរាយ និងព្យាង្គតំរួត

ទោះបីក្បួនក្នុងទំព័រ"គ"នៃវចនានុក្រមពុទ្ធសាសនបណ្ឌិត្យប្រាប់របៀបសរសេររាយព្យាង្គនិងត្រួតព្យាង្គក៏ដោយ ក៏យើងនៅតែឃើញពាក្យមួយចំនួនធំសរសេរបានពីរយ៉ាងដែរ ៖

| | | |
|---|---|---|
| សម្ដែង = សំដែង | សម្ដោះ = សំដោះ | សម្គត = សំគត |
| សម្គុល = សំគុល | សម្ដោក = សំតោក | សម្ទក់ = សំទក់ |
| សម្បក = សំបក | សម្ណាដៃ = សំណាដៃ | សម្បារ = សំបារ |
| សម្បុក = សំបុក | សម្បួរ = សំបួរ | សម្បោរ = សំបោរ |
| សម្ពាយ = សំពាយ | សម្ភោរ = សំភោរ | សម្អប់ = សំអប់... ។ |

(២). អក្សរ"ឡ" និង"ល"

ពាក្យពីរព្យាង្គខ្លះដែលមានសូរ [ល៉] អាចសរសេរបានពីរយ៉ាង ដូចជា ៖

| | | |
|---|---|---|
| ប្រលោះ = ប្រឡោះ | ប្រលូក = ប្រឡូក | ប្រលូញ = ប្រឡូញ |
| ប្រលេះ = ប្រឡេះ | ប្រលែង = ប្រឡែង | ប្រលូស = ប្រឡូស |
| ប្រលង = ប្រឡង | ប្រលង់ = ប្រឡង់ | ស្រលូង = ស្រឡូង... ។ |

(៣). ការសំរួលសំនេរ

- ស្រះពេញតួ "ឭ": រឭក = រលឹក    រំឭក = រំលឹក
- ស្រះពេញតួ "ឮ": ឮសាយ = លឺសាយ    ឮជ័យ = លឺជ័យ
  ឮជា = លឺជា    ឮលាន់ = លឺលាន់
- ស្រះពេញតួ "ឱ ឳ": ឱត = អោត    រឱក = រអោក    ឳ ! = អៅ !
- ព្យញ្ជនៈត្រួតតួ "ហ្វ": ចាងហ្វាង = ចាងវ៉ាង    ហ្វេ = វេ
  គាល់ហ្វៅ = គាល់វ៉ៅ
- ព្យញ្ជនៈត្រួតតួ "ហ្ម": ហ្មត់ចត់ = ម៉ត់ចត់    ហ្មឺន = ម៉ឺន
  ហ្មូត = ម៉ូត    ហ្មេ ! = មេ !
- ព្យញ្ជនៈត្រួតតួ "ហ្ល": ហ្លាក = ឡាក    ហ្លាយ = ឡាយ
  ហ្លេវហ្លែ = ឡេវឡែ    ថៃហ្លាំង = ថៃឡាំង
- ព្យញ្ជនៈត្រួតតួ "ហ្ណ": ហ្ណាំង = ណាំង    ហ្ណ៎ា ! = ណ៎ា !
  ហ្ណ៎ះ ! = ណ៎ះ ! ។

*២. ពាក្យខ្ចីពីបាលីសំស្ក្រឹត*

| | | | |
|---|---|---|---|
| ចតុកោណ | (quadrilatère) | ចតុបាទ | (quadrupède) |
| ឆ្អឹងលលាក្បាល | (os de crâne) | បៀវត្ស | (traitement) |
| គំនរអុស | (bûcher) | ការអត់អោន | (tolérance) |
| ល័ខ | (colorant) | អនុវត្តន៍ | (application) |
| ពិសោធន៍ | (expérience) | អូដ្ឋបូកពីរ | (chameau) |
| តំលៃអនុម័ត | (valeur adoptée) | ភូមិវិទ្យាអនុវត្ត | (géographie appliquée) |
| ឧទ្យានពិសោធ | (arboretum) | | |
| ជញ្ជីងស្វ័យប្រវត្ត | (balance automatique) | | |

បញ្ញាបញ្ញត្ត (intelligence conceptuelle)
ដំណាំពិសោធ (culture expérimentale)។

ឧទាហរណ៍ខាងលើ បង្ហាញអោយឃើញពីទំនោរថ្មីរបស់អង្គការខេមរយានកម្មក្នុងការសរសេរពាក្យគន្លឹះខ្ចីពីបាលីសំស្ក្រឹត តាមជាតិសព្ទដែលដោយ :

- មិនគោរពក្បួនត្រួតព្យញ្ជនៈក្នុងពាក្យសមាសបែបបាលី(ចតុ + កោណ>ចតុកោណ)។
- សរសេរតាមទីតាំងនាម គុណនាម ក្នុងកន្សោមពាក្យ(បញ្ញត្តិ(ន) បញ្ញាបញ្ញត្ត(ន + គុ))។
- ជ្រើសរើសសំនេរពាក្យងាយជាង(ប៉ៀវត្ស គ្មាន"រ៍"ទេ)។
- សំរួលសំនេរពី ឱ ទៅ អោ(ឱន>អោន)។

*ក. សំ.* ក្នុងវចនានុក្រមពុទ្ធសាសនបណ្ឌិត្យ មានតំរាយខ្លះសំរាប់អោយខេមរយានកម្មជ្រើសរើសយកមកអនុវត្ត។

(១). ព្យាង្គរាយ និងព្យាង្គតំរួត

ចំពោះពាក្យដែលអាចសរសេរបានពីរយ៉ាង ខេមរយានកម្មជ្រើសយកព្យាង្គរាយ ៖

សម្បា = សំបា សម្បាច់ = សំបាច់ សម្ភី = សំភី សម្រាជ = សំរាជ... ។

(២). ការត្រួតតួក្នុងបទសមាស

ពាក្យខ្លះត្រូវអនុញ្ញាតអោយសរសេរមិនត្រួតតួបាន ៖

ចតុមុខ = ចតុម្មុខ ចតុលោកបាល = ចតុល្លោកបាល

ពុទ្ធបញ្ញត្តិ = ពុទ្ធប្បញ្ញត្តិ នាមបញ្ញត្តិ = នាមប្បញ្ញត្តិ

បឋមបញ្ញត្តិ = បឋមប្បញ្ញត្តិ វោហារបញ្ញត្តិ = វោហារប្បញ្ញត្តិ... ។

(៣). ពាក្យសរសេរបានពីរយ៉ាង

ចំពោះពាក្យដែលអាចសរសេរបានពីរយ៉ាង ខេមរយានកម្មជ្រើសយកពាក្យណាដែលសរសេរងាយស្រួល ៖

លលា = លលាដ៍ ប៉ៀវត្ស = ប៉ៀវត្សរ៍ ល័ខ = ល័ក្ខ

លក្ខខណ្ឌ = ល័ក្ខខ័ណ្ឌ សម្ភាស = សម្ភាសន៍... ។

(៤). នាម និងកិរិយា(វិគុណនាម)

ពាក្យខ្ចីពីបាលីសំស្ក្រឹតខ្លះមានថ្នាក់នាម និងកិរិយាច្បាស់ ។ ខេមរយានកម្មប្រើពាក្យទាំងនោះសំរបតាមទីកន្លែងពាក្យខ្មែរក្នុងកន្សោមពាក្យ ។

ឧទាហរណ៍

ចាំពិសោធមើលសិន ។ គេត្រូវពិសោធអោយឃើញពិត ។ គាត់ធ្លាប់មានពិសោធន៍ ។ គាត់ប្រព្រឹត្តសុចរិតត្រឹមត្រូវ ។ អ្នកនុះមានប្រព្រឹត្តិត្រឹមត្រូវ ។

*សង្កេត*

ក្នុងទំព័រ៦៥៨មានសេចក្តីដូចតទៅ"តាមបែបវេយ្យាករណ៍ថា បើត្រូវការបង្វែរកិរិយាសព្ទខ្លះអោយជានាម ដោយប្រើពាក្យ ការ ក្តី ដំណើរ សេចក្តី មកផ្សំផងនោះគួរផ្សំជាមួយនឹង កិ ថា ប្រព្រឹត្ត ជា ការប្រព្រឹត្ត ក្តីប្រព្រឹត្ត ដំណើរប្រព្រឹត សេចក្តីប្រព្រឹត ដូចនេះវិញ" ។

(៥). ការសំរួលសំនេរ

ចំពោះពាក្យខ្ចីពីបាលីសំស្ក្រឹតខ្លះ វចនានុក្រមអនុគ្រោះអោយសំរួលសំនេរ ៖

- ស្រះពេញតួ"ឧ": ឧជ្ជល>អុជ = អុច ឧស = អុស
- ស្រះពេញតួ"ឩ": ឩដ្ឋ = អូដ្ឋ ឩន = អូន
- ស្រះពេញតួ"ឫ": ឫស្យា = រឹស្យា ឫទ្ធិ = រឹទ្ធិ សំឫទ្ធ = សំរឹទ្ធ
- ស្រះពេញតួ"ឰ": ឰសួរ = អៃសួរ ឰ ! = អៃ !
- ស្រះពេញតួ"ឱ": ឱ ! = អោ !

ខេមរយានកម្មជ្រើសយកពាក្យផ្តើមដោយ"អ"(អូន)"រ"(រឹទ្ធិ) មកប្រើ ។

*៣. ពាក្យខ្ចីពីបរទេសផ្សេងទៀត*

| | | | |
|---|---|---|---|
| បំពង់ប៊ែម៉ាន់ | (tube Bergman) | ពែក | (Perse) |
| ផលស៊ូល | (effet Joule) | ទែម៉ូម៉ែត | (thermomètre) |
| បារ៉ូម៉ែត | (baromètre) | ព្រីស | (prisme) |
| ព្យុះទីផុង | (typhon) | ភុយស៊ីប | (fusible) |

| | | | |
|---|---|---|---|
| ជីផូស្វាត | (engrais phosphaté) | សឺវ៉ាល្យេ | (chevalier) |
| កែវបាឡុង | (ballon) | ប្រទេសហេឡាត | (Hellade) |
| អាកាសធាតុត្រូពិច | (climat tropical) | ពិចនិច | (pique-nique) |
| អេឡិចត្រូត | (électrode) | កាតូត | (cathode) |
| អាស៊ីត | (acide) | ជនម៉ែត | (Mèdes) |
| ថ្មអាម៉ូញ៉ាក់ | (sel ammoniac) | អាលុយមីញ៉ូម | (aluminium) |
| រ៉ូប៊ីនេ | (robinet) | តួណឺវីស | (tournevis) |
| ធ្យូងតួប | (tourbe) | កូអរដោនេ | (coordonnées) ។ |

ឧទាហរណ៍ខាងលើបង្ហាញអោយឃើញពីទំនោរថ្មីរបស់អង្គការខេមរយានកម្មក្នុងការសរសេរពាក្យគន្លឹះខ្ចីពីបរទេសក្រៅពីបាលីសំស្ក្រឹត តាមសូរសព្ទដោយ ៖

- មិនរក្សាអក្សរមិនអាន (ម៉ែត្រ>ម៉ែត) ។
- ប្រើព្យញ្ជនៈខ្មែរទោលសំរាប់គ្រាប់សូរព្យញ្ជនៈបរទេសទោល(ភុយស៊ីប មិនសរសេរ ហ្វុយហ្ស៊ីប) ។
- មិនសរសេរព្យញ្ជនៈខ្មែរដដែលៗពីរតួដូចក្នុងភាសាបរទេស(បាឡុង មិនមែន បាល្លុង) ។
- ប្រើសញ្ញាព្យញ្ជនៈប្រកបតាមសូរសព្ទ (អាស៊ីត មិនមែន អាស៊ីដ ម៉ិចស៊ិច មិនមែន ម៉ិកស៊ិក មីទិញ មិនមែន មីទិង) ។
- សំរួលសំនេរពាក្យខ្លះ ដូចជា តួប មិនមែន ទួប ។
- មិនរក្សាឥទ្ធិពលមូលភេទ លើកលែងតែព្យញ្ជនៈផ្សំ(កាលីប កាវ៉ែន ការ៉ុត សូលុយស្យុង វ៉ាស្យូ) ។
- មិនប្រើបន្តក់សំរាប់សូរបែប "ម៉ាស បាស ប៉ូតាស" ។
- រក្សា "រ" ទុកសំរាប់សូរព្យាង្គកើតពីព្យញ្ជនៈ និងស្រះ អ រី អ៊ិ (ឡាវ័រសេរ្យ ត្រង់សរដានី (រដ្ឋ) ហែលសិញ៉ូរ(ធានី) រ៉ឺសរ) ។
- និយមអក្សរ "ន" សំរាប់ពាក្យ ដូចជា "រ៉ូប៊ីនេ ឥណ្ឌូនេស៊ី នេវេ កូអរដោនេ ។

*សង្កេត*

តាមរយៈការពិនិត្យឯកសារខេមរយានកម្មនៅសេសសល់ យើងសង្កេតឃើញថា ខេមរយានកម្មនៅសល់"គោលសរសេរ"មួយចំនួនមិនទាន់អនុវត្ត ក្នុងសម័យនោះនៅឡើយទេ ដូចជា"គោលសរសេរ"៖

ក. ក្នុងបញ្ហាទី៦នៃកំនត់ហេតុប្រជុំគណៈកម្មការចំន៊ុះខាងភាសាខ្មែរ ចុះថ្ងៃទី២៦ សីហា ១៩៧២ ស្តីអំពីបញ្ហាដូរតួ"ណ"។

ខ. ក្នុងកំនត់ហេតុប្រជុំនៃគណៈកម្មការបច្ចេកទេសវេយ្យាករណ៍លើកទី២១ ចុះថ្ងៃទី៣ ធ្នូ ១៩៧១ ស្តីអំពីសំនេរ"ប៉ុននោះ"។

គ. ក្នុងកំនត់ហេតុប្រជុំនៃគណៈកម្មការបច្ចេកទេសវេយ្យាករណ៍លើកទី៨៦ ចុះថ្ងៃទី៣ ឧសភា ១៩៧៤ ស្តីអំពីតួ"ញ និង ប"។

រួមសេចក្តីមក យើងឃើញថា ក្នុងរយៈកាល៨ឆ្នាំ ខេមរយានកម្មបានខិតខំយ៉ាងខ្លាំងក្លាក្នុងការបង្កើតក្បួនខ្នាតសំរាប់សរសេរអោយមានលក្ខណៈជាតិ ឯកភាព ងាយស្រួល សមហេតុផល និងអោយស្របតាមតំរាយដែលមានពីមុនមក។

យើងសង្ឃឹមថា វិទ្យាស្ថានភាសាជាតិនឹងខិតខំបន្តស្នាដៃខេមរយានកម្ម ដើម្បីឈានទៅមុខប្រកបដោយជោគជ័យ។

ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០០

សូ មុយឃៀង

## ១. តារាងប្រៀបធៀបសំនេរពាក្យខ្មែរ

| ជំនាក់ទី១ | | ជំនាក់ទី២ |
|---|---|---|
| ចម្ងាយ | distance | ចំងាយ |
| តម្លៃ | valeur | តំលៃ |
| បម្រាប់ | donnée | បំរាប់ |
| កម្ពស់ | hauteur | កំពស់ |
| សម្រិត | décanter | សំរិត |
| សម្រេះ | reprise | សំរេះ |
| សម្លៀកបំពាក់ក្រុង | tenue de ville | សំលៀកបំពាក់ក្រុង |
| មេចំឡុង | vecteur | មេចំលង |
| តំណម្ជូលត្រឡប់ | épissure à torsade inverse | តំណម្ជូលត្រលប់ |
| ប្រឡាយបញ្ជូលទឹក | rigole d'irrigation | ប្រលាយបញ្ជូលទឹក |
| ដូច្នេះ | donc | ដូចនេះ |
| ភ្សាំ | adapter | ផ្សាំ |
| ការហាត់ | exercises | លំហាត់ |
| ការសាយភាយ | diffusion | សំណាយ |
| ការហូរ | ruissellement | លំហូរ |
| ការឆេះ | combustion | ចំហេះ |

| | | |
|---|---|---|
| ការផ្សាំង | domestication | បន្សាំង |
| ការស្វាន | perçage | សង្វាន |
| ឫស | racine | រឹស |
| ផ្កាយឫស | étoile radicale | ផ្កាយរឹស |
| តម្កល់សីតុណ្ហភាពឲ្យនៅដដែល | maintenir la tempéra-ture constante | តំកល់សីតុណ្ហភាពអោយនៅដដែល |
| ចាប់ជើងឱបចង្កេះបោកបញ្ច្រាស | ramassement de jambe et de ceinture à rebours | ចាប់ជើងអោបចង្កេះបោកបញ្ច្រាស |
| ផ្ទេរថយហ្ល័ងរង្វើល | point arrière | ផ្ទេរថយឡាំងរង្វើល |
| នាទីអ្នកហ្វឹកហ្វឺន | rôle de formateur | នាទីអ្នករ៊ឹករ៊ឺន |
| មហាហ្ម័តសករាជ | ère musulmane | មហាម៉ាត់សករាជ |

## ២. តារាងប្រៀបធៀបពាក្យខ្ចីពីបាលីសំស្ក្រឹត

| ជំនាក់ទី១ | | ជំនាក់ទី២ |
|---|---|---|
| ចតុក្កោណ | quadrilatère | ចតុកោណ |
| ចតុប្បាទ | quadrupède | ចតុបាទ |
| ពហុក្កោណ | polygone | ពហុកោណ |
| ឆ្អឹងលលាដ៍ក្បាល | os de crâne | ឆ្អឹងលលាក្បាល |
| ហៀវត្សរ៍ | traitement | ហៀវត្ស |
| គំនរឧស | bûcher | គំនរអុស |
| ការអត់ឱន | tolérannce | ការអត់អោន |
| ការអនុវត្តន៍ | application | អនុវត្តន៍ |
| ការពិសោធន៍ | expérience | ពិសោធន៍ |

## ៣. តារាងប្រៀបធៀបពាក្យខ្ចីពីបារាំង

| ជំនាក់ទី១ | | ជំនាក់ទី២ |
|---|---|---|
| បំពង់ប៊ែរម៉ាន់ | tube Bergman | បំពង់ប៊ែម៉ាន់ |
| កូឡេអុបទែរ | coléoptère | កូលេអុបទែ |
| ទែរម៉ូម៉ែត្រ | thermomètre | ទែម៉ូម៉ែត |
| តារ | tare | តា |
| បារ៉ូម៉ែត្រ | baromètre | បារ៉ូម៉ែត |
| ព្រិស្ម | prisme | ព្រីស |
| ទីគ្រ | Tigre | ទីច(ទន្លេ) |
| ពែក្ស | Perse | ពែក(ប្រទេស) |
| ពីហ្សិះ | pise | ពីស |
| ម៉ាស់ | masse | ម៉ាស |
| ផលហ្ស៊ូល | effet Joule | ផលស៊ូល |
| ព្រៃហ្គារីក | garrigue | ព្រៃការីក |
| ព្យុះទីហ្វុង | typhon | ទីផុង(ព្យុះ) |
| ខ្យល់ហ្វឺន | foehn | ខ្យល់ផឺន |
| ហ៊្វុយស៊ីប | fusible | ភុយស៊ីប |
| ជីហ្វូសហ្វាត | engrais phosphaté | ជីផូស្វាត |
| ស្ហឺវ៉ាលីយេរ | chevalier | សឺវ៉ាលៀ |
| បាល្លុង | ballon | បាឡុង |
| អាស្សីរីវិទ្យា | assyriologie | អាស៊ីរីវិទ្យា |

| | | |
|---|---|---|
| ប្រទេសហេល្លាដ | Hellade | ហេឡាត(ប្រទេស) |
| ព្រះបាទហាម្មូរ៉ាប៊ី | Hammourabi | ហាម្មូរ៉ាប៊ី(ព្រះបាទ) |
| ព្រះបាទអាស្សូរបានីប៉ាល | Assurbanipal | អាស្សូបានីប៉ាល់(ព្រះបាទ) |
| អាកាសធាតុត្រូពិក | climat tropical | អាកាសធាតុត្រូពិច |
| លក្ខណៈមេកានិក | propriétés mécanique | លក្ខណៈមេកានិច |
| ពិកនិក | pique-nique | ពិចនិច |
| អេឡិកត្រូដ | électrode | អេឡិចត្រូត |
| ខ្យងម្យូរិក | murex | មុយរិច(ខ្យង) |
| ប្រទេសក្រិក | Grèce | ក្រិច(ប្រទេស) |
| កាតូដ | cathode | កាតូត |
| អាណូដ | anode | អាណូត |
| អាស៊ីដ | acide | អាស៊ីត |
| អានីឌ្រីដ | anhydride | អានីឌ្រីត |
| ជនម៉ែដ | Mèdes | ម៉ែត(ជន) |
| កុមប៉ុស | compost | កុំប៉ុស |
| ស៊ុលហ្វាតអាម៉ូនីញ៉ូម | sulfate d'ammonium | ស៊ុលផាតអាម៉ូញ៉ូម |
| ថ្មអាម៉ូនីញ៉ាក់ | sel ammoniac | ថ្មអាម៉ូញ៉ាក់ |
| អាលុយមីនីញ៉ូម | aluminium | អាលុយមីញ៉ូម |
| ទួណឺវីស | tournevis | តួណឺវីស |
| ធ្យូងទួប | tourbe | ធ្យូងតួប |

ក្រសួងអប់រំជាតិ និង វប្បធម៌
គណៈកម្មការចំរុះខាងភាសាខ្មែរ

សាធារណរដ្ឋខ្មែរ

## កំណត់ហេតុប្រជុំគណៈកម្មការចំរុះខាងភាសាខ្មែរ

ថ្ងៃប្រជុំ : ថ្ងៃទី ២៦ ខែមីនា ១៩៧២
វេលាប្រជុំ : ០៨,០០ ដល់ ១១,០០
កន្លែងប្រជុំ : អគ្គលេខាធិការដ្ឋាន ខេមរយានកម្ម
សមាជិក :

ក- មកប្រជុំ

លោក ឈួន សុខម អនុប្រធាន ជាប្រធានប្រជុំ
- ខៀវ ស្លឹង សមាជិក
- ពូ ធី -
- ចាក់ គួង -

ខ- ខានប្រជុំ

ព្រះភិក្ខុ ពុង ខាត់ ជាប់រវល់
លោក ព្រុំ ម៉ុល -
- ចាន់ គន្ធ -
អ្នកស្រី ឃុត ម៉ែត -

គ- ភ្ញៀវមកប្រជុំដែរ

លោក ម៉ែក ឃុត អគ្គលេខាធិការដ្ឋានខេមរយានកម្ម

លិខិតបង្គាប់ការ : លេខ ៤២៥ អតស-ប ចុះថ្ងៃទី ២៤-០៤-៧២ របស់ ក្រសួងអប់រំជាតិ និង វប្បធម៌

របៀបវារៈ : ពិនិត្យគោលប្រែពាក្យតាមសំណើរបស់អង្គការ ខេមរយានកម្ម ។

បញ្ហាទី ១

បញ្ហា ប្រកប 'ក' ឬ 'ច' សំរាប់កត់សូរព្យាង្គដូចតទៅនេះ:

*- ec, - ech, - eck, - ect, - ecte, - eque, - ecque, - ex...
*- ic, - ich, - ick, - ict, - ig, - igle, - igre, - igue, - ik, - ique...
*- uc, - ucre, - uk, - ug, - ugue, - ux, - uxe...

ពិភាក្សា

លោក ឈួន សុខម : ស្រៈ "i" បរទេសអាចប្រកបជាមួយនឹង "k" បាន តែស្រៈ 'អិ' ខ្មែរមិនអាចប្រកបនឹង 'ក' ទេ មានតែជាមួយ 'ច' ព្រោះខ្យល់ 'អិ' និង 'ច' នៅជិតគ្នា ហើយព្យញ្ជនៈប្រកប 'ច' ជាសូរចូល មិនដូចជាព្យញ្ជនៈប្រកប ( k ) បរទេសជាសូរចេញ ហើយស្រៈអិជាស្រៈខ្លីផង មិនអាចរត់ទៅប្រកបនឹង 'ក' ឯទៀតក្រោយទាន់ទេ ។

លោក ខៀវ ស្លឹង ការប្រកបនឹង 'ក' ច្រើនតែមានសូរ 'ច'

./. ទំព័រទី ២

អង្គប្រជុំសំរេច ស្រៈ ' អិ - អឹ - អេ ' ខ្លីត្រូវប្រកបនឹង ' ច ' ដូចនេះ :

| | | |
|---|---|---|
| Grec | ត្រូវសរសេរប្រកបនឹង ' ច ' គឺ | ក្រិច |
| hectare | - ដ - | ហិចតា |
| Liberec | - ដ - | លីបេរិច |
| technique | - ដ - | តិចនិច |
| catholique | - ដ - | កាតូលិច |
| Amérique | - ដ - | អាមេរិច |
| Lux | - ដ - | លុច |
| Pollux | - ដ - | ប៉ូលុច |
| duc | - ដ - | ឌុច |

បញ្ហាទី ២ ពូប្រកប ' ង ' និង ' ញ '

គេបានមើលឃើញថា ពូប្រកប ' ង ' និង ' ញ ' ក៏មានលក្ខណៈដូច ក និង ច ដែរ

អង្គប្រជុំសំរេច : ឲ្យប្រកបស្រៈ ' អិ ' ខ្លី និង ' ញ ' ដូចជា ' ច ' ប្រកបដែរ ។

| ឧទាហរណ៍ | ប្រកបនឹង ' ញ ' |
|---|---|
| bulding | ប៊ុលឌិញ |
| camping | កាំពិញ |
| Manning | ម៉ានិញ |
| Meeting | មីទិញ |
| ring | រិញ |
| sterling | ស្ទែលិញ |
| Harding | ហាឌិញ |

បញ្ហាទី ៣ ពូប្រកប ' ដ ' និង ' ត '

ពិភាក្សា : លោក ថាច់ ឌួង បានបញ្ជាក់ថា ពាក្យខ្លះប្រកបនឹង ' ដ ' នាំឲ្យសិទ្ធិសំរេចលំនាំបង្កើតពាក្យមួយថ្មីទៀត ដូចជា :

lycopode = លីកូប៉ូដ ; lycopodium លីកូប៉ូដ្យូម

soude = សូដ sodium = សូដ្យូម

លោក ឃួន សុខុម : បើមានសូរដូចនេះ ខ្មែរសង្កត់សូរទៅលើដើម ' ឃ ' នឹងសូរស្រៈ ឯជាតុទីខត្រូវទន្ទ្រាយជាសូរខ្លាំងទាំងអស់ ដូចជា ' ឈ្មិត ' ពុំ ក្ហា ' ក្បិត ' ទេ ។

អង្គប្រជុំសំរេច យកពូ ' ត ' ប្រកបជំនួស ' ដ ' វិញ ដូចជា

| ឧទាហរណ៍ | សរសេរប្រកបនឹង ' ត ' |
|---|---|
| acide | អាស៊ីត |
| soude | សូត |
| sodium | សូត្យូម |
| lycopode | លីកូប៉ូត |
| lycopodium | លីកូប៉ូត្យូម |
| Belgrade | បែលក្រាត |

បញ្ហាទី ៤ ពាក្យមូល

១- ជាទូទៅ ត្រូវប្តូរពាក្យម្លាតិ៍ឲ្យយកជាពាក្យផ្សំ តាមកំលាយខ្មែរ ។

ឧ- ការកើត -> កំណើត

ការដើរ -> ដំណើរ

ការរាយ -> រណាយ

អ្នកតែង -> តំណែង

សន្និដ្ឋាន : អង្គប្រជុំបានពិភាក្សាអំពីបញ្ហារក្សាឫសរបស់ពាក្យដើម នៅក្នុងពាក្យឈ្នួល :

១_ ក ា រ ន៍ ព្ រា ន៍

អង្គប្រជុំសំរេចឱ្យរក្សា ឫស ដើម ដូចនេះ ប៉ុន្តែសុំឱ្យអនុវត្តទៅបន្តិច ៗ ។

២_ បំពាក់ពាក្យ ឬលពីរព្យាង្គដែលមានព្យញ្ជនៈដើមដូចគ្នា អង្គប្រជុំយល់ស្របតាមសំណើរបស់គណៈកម្មការអនុម័តពាក្យដែលថា ត្រូវរំលួសទាំងពីរព្យាង្គ ។

១_ ការចាត់ចែង → ចំណាត់ចែង

ការខកខាន → កំហាកំហាន

ប៉ុន្តែអង្គប្រជុំចាំសុំយោបល់ព្រះភិក្ខុ ទាំង ២ ជា ពី ជាប្រធានគណៈកម្មការសិន

៣_ អង្គប្រជុំយល់ស្របតាមគណៈកម្មការអនុម័តពាក្យ ដែលថា ត្រូវរំលួសតែព្យាង្គទី ១ បំពាក់ពាក្យ ឬល ពីរព្យាង្គ ដែលមានព្យញ្ជនៈដើមស្រដៀងគ្នា នោះ ។

១_ ការចំណាំ — ចំរិចាំ

ការសោយការ — ចំណាយការ

៤_ អង្គប្រជុំយល់ស្របទាំងស្រុង បំពាក់ការលើកលែងរបស់គណៈកម្មការអនុម័តពាក្យ ដែលថា មិនបាច់ប្តូរពាក្យខ្លះៗនោះ ៗ

| ឧទាហរណ៍ | មិនប្តូរ |
| --- | --- |
| ការរៀបចំ | របៀបចំ |
| ការកាត់ទេស | កំណាត់ទេស |
| ការទិញខ្ចី | អំណោយខ្ចី |

## បញ្ហាទី ៥ បញ្ហារាយព្យាង្គ

លោក ទៀប ថ៉ន ស្នើសុំឱ្យសរសេរពាក្យពីរព្យាង្គដែលមានព្យាង្គទី១ប្រកប នឹង "ម" ជារបៀបតាមគ្នា ៗ

១_ សម្លាប់ → សំលាប់

តម្លៃ → តំលៃ

ពិភាក្សា : លោក ហួត សុខម គណៈកម្មការបច្ចេកទេសវេយ្យាករណ៍ សុំឱ្យលុបសញ្ញាដកឃ្លា ឬ និគ្គហិត "ំ" ចោលហើយប្រើ "ម" ជំនួសវិញ ដូចនេះបញ្ហាសរសេររាយព្យាង្គ ត្រូវចោលចោលដូចតទៅ :

សម្លាប់ → សម់លាប់

តម្លៃ → តម់លៃ

បំពេញ → បម់ពេញ

បំប្រាង → បម់ប្រាង

ម្យ៉ាងទៀតអង្គប្រជុំសង្កេតឃើញថា បើលុបជំនើស "ំ" ចោល គេត្រូវតែសរសេរពាក្យច្រើនព្យាង្គតំរួតគ្នា ៗ

១_ បំភ្លេច → បម្ភេច

បំផ្លាញ → បម្ផ្លាញ

កំសាន្ត → កម្សាន្ត

សំអ → សម្អ

អង្គប្រជុំសំរេច : ឱ្យសរសេរជាព្យាង្គតាមលំនាំដើមតទៅទៀត ដូចជា :

| | | | |
| --- | --- | --- | --- |
| សំលាប់ | តំលៃ | កំសាន្ត | សំអ |
| បំពេញ | បំប្រាង | បំភ្លេច | បំផ្លាញ |
| តំរួត | តំរង់ | ចំណាប់ ។ល។ | |

បញ្ហាទី ៦ បញ្ហាដូច "ណ" ដែលចេញពីកំលាយ ដែលមានឫស "ក-ច-ជ-ព-ប-ស- និង អ" ត្រូវទៅជា "ន" ។

ឧ- កំណើត ⟶ កំនើត

ចំណែក ⟶ ចំនែក

ជំណាំ ⟶ ជំនាំ

ពំណែង ⟶ ពំនែង

បំណែក ⟶ បំនែក

សំណួរ ⟶ សំនួរ

អំណាច ⟶ អំនាច

គណៈប្រជុំសំរេច ៖ យកតួ "ន" ជំនួស "ណ" ទាំងអស់

ប្រធានប្រជុំ

ឃួន សុខម្ភូ

លេខាធិការប្រជុំ

រ៉ែកន ឃុន

ក្រុមប្រឹក្សារដ្ឋមន្ត្រី
ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

លេខ: 261 ល.ស

សាធារណរដ្ឋប្រជាមានិតកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ភ្នំពេញ, ថ្ងៃទី 25 ខែ 04 ឆ្នាំ ១៩៨៥

រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី
សូមជំរាបមក

ស.ម រដ្ឋមន្ត្រីក្រសួងអប់រំ

កម្មវត្ថុ: ពង្រាងសេចក្តីសំរេចបង្កើតគណៈកម្មាធិការជាតិ ស្តីពីការប្រើប្រាស់អក្សរខ្មែរ ។

យោង: លិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ លេខ ២៥៥ ខ.ក.ប.ឧ ចុះថ្ងៃទី ១៦-៤-១៩៨៥ ។
- កំណត់ហេតុនៃសម័យប្រជុំក្រុមប្រឹក្សារដ្ឋ ថ្ងៃទី ០៥-៤-១៩៨៥ ។

តបតាមកម្មវត្ថុ និងលិខិតយោងខាងលើ ដែលក្រសួងអប់រំបានទទួល ១ ច្បាប់ដែរ ខ្ញុំសូមជំរាប ស.ម រដ្ឋមន្ត្រីជ្រាបថា: តាមស្មារតីនៃសម័យប្រជុំក្រុមប្រឹក្សារដ្ឋ ថ្ងៃទី ០៥-៤-១៩៨៥ ចំពោះបញ្ហាដែលលើកឡើងពិភាក្សា ស្តីពីការប្រើអក្សរខ្មែរ ក្រុមប្រឹក្សារដ្ឋមន្ត្រី សូមស្នើអោយក្រសួងអប់រំ:

១- អនុវត្តតាមក្បួនរបៀបចាស់ និងរក្សាការសរសេរក្នុង ៦ ឆ្នាំកន្លងមក ។

២- ធ្វើតារាង ស្តីពីពាក្យដែលបានប្រើក្នុង ៦ ឆ្នាំកន្លងមក និងពាក្យដែលធ្លាប់ប្រើតាមរបៀបទម្លាប់ចាស់ ។

៣- ធ្វើព្រាងអនុក្រឹត្យ ដើម្បីបង្កើតគណៈកម្មាធិការជាតិមួយ ស្តីពីការប្រើប្រាស់អក្សរខ្មែរ ដោយបញ្ជាក់ច្បាស់ពីតួនាទីភារកិច្ច សមាសភាពនៃគណៈកម្មាធិការ ព្រោះមុខងារនៃកម្មាធិការរបស់ក្រសួងពាក់ព័ន្ធដែលត្រូវចូលរួម ហើយផ្ញើមកក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីពិនិត្យ និងស្នើទៅគណៈចាត់តាំងមជ្ឈិម និងគណៈលេខាមជ្ឈិមបក្ស សំរេច ។

អាស្រ័យហេតុនេះ សូម ស.ម ជ្រាប និងចាត់ចែងអនុវត្តតាមគតិដែលខាងលើនេះអោយបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។

ជូនពរ សុខភាពល្អ និង ជ័យជំនះ

ជ.រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

[illegible]- ណាល់

ចំលងជូន :
- ខុទ្ទកាល័យមជ្ឈិមបក្ស
- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ
- គណៈចាត់តាំងមជ្ឈិម
- គណៈឃោសនាអប់រំមជ្ឈិម

"ដើម្បីមេត្តាជ្រាបជាពត៌មាន"

- ឯកសារ.